INTERNATIONAL RIVERS
people • water • life

# ការសិក្សាពិនិត្យឡើងវិញដោយអ្នកជំនាញឯករាជ្យ លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឯកសារយោងផ្សេងទៀតរបស់គម្រោងទំនប់ ប៉ាក់ បេង

អង្គការទន្លេអន្តរជាតិបានជួលអ្នកជំនាញបួននាក់ ដើម្បីសិក្សាពិនិត្យឡើងវិញលើឯកសារនានារបស់គម្រោងទំនប់ប៉ាក់ បេង ដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅ លើគុណភាពនៃរបាយការណ៍នានា ដែលបានរៀបចំឡើងក្នុងនាមអ្នកសាងសង់ទំនប់ ដែលជាក្រុមហ៊ុនអគ្គីសនី ដាថាង (Datang Power Company) ។ ឯកសារដែលត្រូវពិនិត្យឡើងវិញ រួមមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវារីអគ្គីសនី ប៉ាក់ បេង ("ទំនប់ប៉ាក់ បេង") (Environmental Impact Assessment for the Pak Beng Hydropower Project ("the Pak Beng Dam")) និងឯកសារយោងផ្សេងទៀត ដូចជាការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថានឆ្លងដែន និងការវាយតម្លៃហេតុប៉ះពាល់រួម (Transboundary Environmental and Social Impact Assessment & Cumulative Impact Assessment) ការវាយតម្លៃហេតុប៉ះពាល់សង្គម (Social Impact Assessment) ផែនការសកម្មភាពអំពីការតាំងទីលំនៅនៅកន្លែងថ្មី (Resettlement Action Plan) និងរបាយការណ៍ពីការរៀបចំផ្លូវចរាចរណ៍ត្រី (Fish Passage Design Report)។ អ្នកជំនាញទាំងនេះ មានជំនាញចម្រុះលើបញ្ហាជាច្រើន រួមមានការកាត់បន្ថយហេតុប៉ះពាល់ជលផល ការតាំងទីលំនៅកន្លែងថ្មី ហេតុប៉ះពាល់សង្គម ហេតុប៉ះពាល់យេនឌ័រ ច្បាប់បរិស្ថាន និងបទដ្ឋានអន្តរជាតិនានា សម្រាប់ការវាយតម្លៃហេតុប៉ះពាល់។

ជារួម ការសិក្សាពិនិត្យឡើងវិញនេះ បានរកឃើញថា ឯកសារគម្រោងទាំងនោះបង្ហាញនូវរូបភាពមានកម្រិតតិចតួចស្តួចស្តើងបំផុត លើការប៉ាន់ស្មានពីហេតុប៉ះពាល់សង្គម និងបរិស្ថានរបស់គម្រោងទំនប់ ប៉ាក់ បេង ហើយជាពិសេស មិនបានយកចិត្តទុកដាក់ក្នុងការវាយតម្លៃហេតុប៉ះពាល់រួម និងហេតុប៉ះពាល់ឆ្លងដែនពីគម្រោងនេះឡើយ។

## <u>ការរកឃើញសំខាន់ៗ</u>

ទិន្នន័យដែលបានប្រើក្នុងរបាយការណ៍ រួមទាំងព័ត៌មានអំពីជលផល ជលវិទ្យា និងដីល្បាប់ គឺភាគច្រើនបានដកស្រង់ពីការសិក្សានានា ដែលបានធ្វើក្នុងឆ្នាំ ២០១១ ឬមុនឆ្នាំ ២០១១ទៀត ដោយមានការពិនិត្យពិច័យតិចតួចទៅលើព័ត៌មានថ្មីៗ និងការផ្លាស់ប្តូរដែលមានក្នុងទន្លេមេគង្គ ដែលរួមទាំងការសាងសង់ទំនប់វារីអគ្គីសនីសាយ៉ាប៊ូរី (Xayaburi) និងទំនប់ ដន សាហុង (Don Sahong)។ ជារួម ការសិក្សាបានបង្ហាញពីកង្វះខាតការយល់ដឹងទៅលើប្រព័ន្ធអេកូឡូស៊ីដ៏ស្មុគស្មាញរបស់ទន្លេមេគង្គ និងការអភិវឌ្ឍនានាដែលកំពុងមានស្រាប់ក្នុងទន្លេនេះ។ ទិន្នន័យដើមគ្រាដែលមិនគ្រប់គ្រាន់ មានន័យថាវិធានការបន្ធូរបន្ថយ ដែលបានស្នើដើម្បីកាត់បន្ថយការបាត់បង់ ផ្លូវចរាចរណ៍ត្រី និងដើម្បីឆ្លើយតបទៅនឹង ហេតុប៉ះពាល់សង្គមនៃទំនប់ប៉ាក់ បេង គឺមិនមែនជាដំណោះស្រាយដែលគួរឱ្យជឿទុកចិត្តនោះឡើយ។

កង្វះខាតសំខាន់ៗក្នុងការសិក្សាដែលបានរកឃើញតាមរយៈការពិនិត្យឡើងវិញដោយឯករាជ្យនេះរួមមាន៖

- យោងតាមសំណាកដែលមិនសមល្មម ព័ត៌មានបានមកទាំងនោះ គឺមិនគ្រប់គ្រាន់សម្រាប់វិនិច្ឆ័យពីហានិភ័យនៃធនធានត្រី និងសម្រាប់វាយតម្លៃការប៉ាន់ស្មានហេតុប៉ះពាល់របស់ទំនប់ ប៉ាក់ បេង មកលើធនធានត្រីទន្លេមេគង្គក្នុងទីតាំងទំនប់ និងផ្នែកខាងលើ និងខាងក្រោមនៃទីតាំងនោះទេ។ វិធានការនានាដែលបានស្នើឡើងដើម្បីបន្ធូរបន្ថយហេតុប៉ះពាល់លើផ្លូវចរាចរណ៍ត្រី មិនទាន់ត្រូវបានគេពិសោធន៍ក្នុងទន្លេមេគង្គ ដូចនេះវាមិនអាចយកមកវាយតម្លៃប្រសិទ្ធិភាពរបស់វាក្នុងបរិបទទន្លេនេះបានឡើយ។
- ការវាយតម្លៃ និងឯកសារហេតុប៉ះពាល់សង្គមនៃទំនប់ ប៉ាក់ បេង សម្រាប់សហគមន៍ដែលត្រូវតាំងលំនៅថ្មី និងសហគមន៍ដែលនៅផ្នែកខាងលើនិងខាងក្រោមនៃគម្រោងនេះ មានកម្រិតតិចតួច។ ផែនការសំណង និងដំណោះស្រាយនានា គឺយោងតាមការសន្មត់ដែលមិនប្រាកដប្រជា និងមិនមានមូលដ្ឋានច្បាស់លាស់ ដោយភាគច្រើនយោងតាមវិធីដែលបានប្រើក្នុងគម្រោងវារីអគ្គិសនីខ្នាតធំផ្សេងទៀតក្នុងប្រទេសឡាវ ដែលមិនបានឆ្លើយតបដូចការសន្យាថា នឹងធ្វើឱ្យជីវភាពប្រជាជនល្អដូចដើម ឬកាត់បន្ថយការប៉ះពាល់បរិស្ថាននោះឡើយ។
- ការវាយតម្លៃមិនគ្រប់គ្រាន់នៃហេតុប៉ះពាល់របស់ទំនប់ ប៉ាក់ បេង មកលើសហគមន៍ក្នុងប្រទេសថៃ ជាលទ្ធផលឃើញថា មានការផ្លាស់ប្តូរប្រព័ន្ធទឹកក្នុងទន្លេ និងការរារាំងច្រកផ្លូវចរាចរណ៍ត្រី ដូចជាត្រីគល់រាំង ដែលប្រឈមនិងគ្រោះថ្នាក់បាត់បង់។ ការបន្ថយតម្លៃ នៃសារសំខាន់ធនធានជលផល និងជីវភាពប្រជាជនដែលពឹងអាស្រ័យលើទន្លេមេគង្គក្នុងប្រទេសថៃ ដោយផ្អែកលើទិន្នន័យដើមគ្រាហួសសម័យ និងមិនគ្រប់គ្រាន់។
- អវត្តមាននៃការចូលរួមជាសាធារណៈដោយពេញលេញ ក្នុងការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន មិនមានការពិភាក្សាពិគ្រោះយោបល់ជាមួយសហគមន៍ ដែលរងផលប៉ះពាល់ដោយគម្រោងទំនប់នេះ ហើយក៏គ្មានការសិក្សាពីសក្តានុពលហេតុប៉ះពាល់ឆ្លងដែនផ្សេងៗ ក្នុងប្រទេសកម្ពុជា ឬប្រទេសវៀតណាមទេ។
- គ្មានការពិនិត្យពិច័យនៃហេតុប៉ះពាល់រួមនៃគម្រោងនេះ ដោយរួមផ្សំជាមួយនឹងទំនប់ផ្សេងៗទៀតដែលមានក្នុងទន្លេមេគង្គ និងអាងរបស់វា ដោយរាប់បញ្ចូលទាំងទំនប់វារីអគ្គិសនី សាយ៉ាប៊ូរី (Xayaburi) និងទំនប់វារីអគ្គិសនី ដន សាហុង (Don Sahong)។

ការសិក្សាពិនិត្យឡើងវិញនេះ សន្និដ្ឋានថា ឯកសារនានារបស់គម្រោងទំនប់ ប៉ាក់ បេង ដែលបានដាក់ជូនគណៈកម្មការទន្លេមេគង្គ (MRC) ស្របតាមនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) មិនបានវាយតម្លៃហេតុប៉ះពាល់សង្គមនិងបរិស្ថានឱ្យបានគ្រប់ជ្រុងជ្រោយទេ ហើយក៏មិនបានវាយតម្លៃឱ្យគ្រប់គ្រាន់លើលទ្ធភាពសម្រេចបាននៃវិធានការបន្ធូរបន្ថយហេតុប៉ះពាល់ ដែលមាននោះដែរ។ ជាងនេះទៅទៀត ឯកសារដែលមានទាំងនេះ មិនបានពិចារណាលើការសាងសង់ទំនប់ ប៉ាក់ បេង ដោយរួមបញ្ចូលទាំងទំនប់ផ្សេងទៀតដែលកំពុងតែសាងសង់ និងស្ថិតក្នុងផែនការគម្រោងសាងសង់ក្នុងទន្លេ និងអាងទន្លេមេគង្គនេះទេ។

ទិន្នន័យដើមគ្រាដែលគួរឱ្យជឿជាក់ ពេញលេញ នាបច្ចុប្បន្ននេះ មានសារៈសំខាន់ណាស់សម្រាប់ដឹងពីហានិភ័យ ដែលអាចកើតមាន ជាមួយនឹងវត្តមានទំនប់ ប៉ាក់ បេង ទៅលើផលផល ជលសាស្ត្រ និងលំហូរល្បាប់ ដោយរួមមានទាំងហេតុប៉ះពាល់លើជីវភាពសហគមន៍តាមដងទន្លេមេគង្គ។ ទិន្នន័យដើមគ្រាដែលគ្រប់គ្រាន់ ក៏មានសារៈសំខាន់ណាស់ដែរ សម្រាប់រៀបចំវិធានការបន្ធូរបន្ថយដែលមានលក្ខណៈសមរម្យ និងទៅតាមបរិបទជាក់លាក់ ក៏ដូចជាកសាងប្រព័ន្ធតាមដានប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ ឧទាហរណ៍ការវាយតម្លៃផ្នែកបរិស្ថានជាយុទ្ធសាស្ត្រ ដែលធ្វើឡើងដោយគណៈកម្មការទន្លេមេគង្គ (MRC-Commissioned Strategic Environmental Assessment) បានព្រមានថា "ប្រសិនបើច្រកសម្រាប់ត្រីឆ្លងកាត់ពិតជាជោគជ័យមែននោះ ការធ្វើច្រកទាំងនេះគួរត្រូវគេពិចារណាតាំងពីជំហ៊ានរៀបចំដំបូងបំផុត កំឡុងពេលនៃការសម្រេចចិត្តលើទីតាំងទំនប់ និងរៀបចំប្លង់ផ្សេងៗ ហើយច្រកទាំងនេះ ត្រូវតែមានសម្រាប់ប្រភេទត្រីជាក់លាក់ ដែលបានកំណត់ទុកជាមុន"។[1]

**<u>អនុសាសន៍សំខាន់ៗ</u>**

ដោយរកឃើញថា មានកង្វះខាតយ៉ាងធ្ងន់ធ្ងរក្នុងឯកសារគម្រោងទំនប់ ប៉ាក់ បេង អ្នកសាងសង់ក្នុងគម្រោងនេះ ត្រូវសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្មីមួយទៀត ដោយរួមបញ្ចូលទាំងទិន្នន័យដែលប្រមូលបានក្នុងរយៈពេល១០ឆ្នាំចុងក្រោយ និងការសិក្សាថ្មីៗ អំពីធនធានជលផល ជលសាស្ត្រ និងហេតុប៉ះពាល់ឆ្លងដែន។

- កម្មវិធីចម្រុះមួយដែលរួមមានការសិក្សាស្រាវជ្រាវ និងការតាមដានលើបរិស្ថាន គួរត្រូវធ្វើភ្លាមៗ មុនពេលមានការសម្រេចចិត្តលើគម្រោងទំនប់ ប៉ាក បេង បន្ថែមទៀត។ វាមានសារៈសំខាន់ណាស់ ដែលការសិក្សាដើមគ្រា ត្រូវបានធ្វើឡើងមុនពេលមានការអនុញ្ញាតឱ្យសាងសង់ទំនប់ និងមុនពេលមានសកម្មភាពលើទីលំនៅ និងមុនពេលមានការប៉ះពាល់ដល់បរិស្ថាន។
- ការសិក្សាតានដានបរិស្ថានគួររួមបញ្ចូលៈ
    - ព័ត៌មានពីការប្រមូលផលត្រីក្នុងតំបន់គម្រោងគ្រប់រដូវកាលទាំងអស់ និងយ៉ាងហោចណាស់សម្រាប់រយៈពេលពីរឆ្នាំចុងក្រោយ ដោយប្រើបច្ចេកទេសនេសាទសកម្មនិងអសកម្មផ្សេងៗគ្នា។ ប្រភេទត្រីប្រចាំតំបន់ និងត្រីឆ្លងដែន គួរត្រូវកំណត់ឱ្យគ្រប់ជ្រុងជ្រោយជាមុនផងដែរ។ ការតាមដានគួរចេញជាតួលេខនៃចំនួន និងជីវចម្រុះរបស់ប្រភេទត្រីប្រចាំតំបន់ និងតួលេខ និងរដូវកាលនៃត្រីមេពូជ ដែលហែលឡើងទឹក ព្រមទាំងពង កូនញាស់ និងកូនតូចៗ ដែលបណ្តែតខ្លួនតាមបណ្តាយខ្សែទឹកត្រឡប់មកក្រោមវិញ ។
    - ការសិក្សានៅនឹងកន្លែង និងនៅមន្ទីរពិសោធន៍ គួរត្រូវធ្វើឡើងដើម្បីវាយតម្លៃភាពអាចទៅរួចដែលថា ការបន្ធូរបន្ថយច្រកផ្លូវចរាចរណ៍ត្រីឡើងទឹកដែលបានស្នើឡើង នឹងពិតជាមានប្រសិទ្ធិភាព ហើយលទ្ធផលនៃច្រកតាមស្លាបចក្រ របស់ទំនប់ដើម្បីឱ្យត្រីហែលចុះមកខាងក្រោមទំនប់វិញ។
- ត្រូវមានការសិក្សាឱ្យគ្រប់ជ្រុងជ្រោយអំពីហេតុប៉ះពាល់សង្គម ដែលអាចមានលើផ្នែកខាងលើ និងខាងក្រោមនៃទីតាំងទំនប់ ដែលទូរទាត់ជាតួលេខនៃចំនួនសហគមន៍ពិតប្រាក ដែលនឹងទទួលរងផលប៉ះពាល់ និងផ្អែកលើទិន្នន័យនាពេលបច្ចុប្បន្ន។ ការសិក្សានេះ ត្រូវរួមបញ្ចូលទិន្នន័យដើមគ្រា

[1] ការវាយតម្លៃជាយុទ្ធសាស្ត្រផ្នែកបរិស្ថាន នៃទំនប់វារីអគ្គីសនីក្នុងតួទន្លេមេគង្គ ដែលរៀបចំសម្រាប់គណៈកម្មការទន្លេមេគង្គ។ ឯកសារចុងក្រោយ ទំព័រទី ១៦។

ដែលមានព័ត៌មានចម្រុះសម្រាប់សហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោល ដោយសារទំនប់ ប៉ាក់ បេង ដោយយោងតាមបរិបទវប្បធម៌ សេដ្ឋកិច្ច និងសង្គមជាក់លាក់។ របាយការណ៍នៃការសិក្សានេះ ត្រូវផ្តល់ព័ត៌មានបន្ថែមអំពីរបៀបនៃទំនប់ ប៉ាក់ បេង អាចនឹងប៉ះពាល់មួយផ្នែកធំដល់ស្ត្រី។

- យន្តការនានាដើម្បីដោះស្រាយហេតុប៉ះពាល់សង្គម ឲ្យបានពេញលេញត្រូវតែបង្កើតឡើង សម្រាប់សហគមន៍ដែលនឹងតាំងលំនៅថ្មី និងសហគមន៍ដែលស្ថិតនៅផ្នែកខាងលើ និងខាងក្រោមនៃទំនប់ ដែលនឹងទទួល ការរំខានដល់ជីវភាពរបស់ពួកគេ ។ ការវាយតម្លៃឯករាជ្យនៃដីដែលនឹងផ្តល់សម្រាប់ការតាំងលំនៅថ្មី ត្រូវតែធ្វើឡើងជាបន្ទាន់ ដោយមានការចូលរួមពីប្រជាជនដែលនឹងត្រូវប្តូរទីលំនៅថ្មីនោះ។
- ត្រូវមានយន្តការតាមដានឯករាជ្យមួយដើម្បីឱ្យក្រុមហ៊ុន និងមន្ត្រីរដ្ឋាភិបាលទទួលខុសត្រូវ ប្រសិនបើផលប្រយោជន៍ពីការតាំងលំនៅថ្មីនិងសំណងផ្សេងៗ ដែលបានសន្យាកន្លងមកមិនបានកើតមាន ឬប្រសិនបើ ហេតុប៉ះពាល់នៃគម្រោងនេះ មានទំហំធំជាងកិច្ចព្រមព្រៀង និងឯកសារគម្រោង ដែលបានប៉ាន់ស្មានទុកជាមុន។
- ការសិក្សាបន្ថែមទៀតលើហេតុប៉ះពាល់ដោយទំនប់ ប៉ាក់ បេង ក្នុងប្រទេសថៃ គឺត្រូវតែមានជាចាំបាច់ ដោយរាប់បញ្ចូលទាំងទិន្នន័យដើមគ្រាឱ្យបានគ្រប់ជ្រុងជ្រោយអំពីជលផល និងជីវភាពសហគមន៍ជនជាតិថៃ ។
- ការវាយតម្លៃហេតុប៉ះពាល់សង្គមនិងបរិស្ថានឆ្លងដែននេះ ត្រូវតែធ្វើម្តងទៀត ដើម្បីរួមបញ្ចូលទិន្នន័យដែលទទួលបានក្នុងរយៈពេល១០ ឆ្នាំចុងក្រោយ។ របាយការណ៍នៃការវាយតម្លៃនេះ គួរបញ្ចូលផងដែរ នូវវិធីទូទាត់ផ្នែកសេដ្ឋកិច្ចនៃផលប៉ះពាល់ ការវាយតម្លៃជាទឹកប្រាក់ចុងក្រោយនៃផលត្រីដែលចាប់បាន និងធនធានជលផល និងតម្លៃសំណងសម្រាប់ការបាត់បង់ផលត្រី និងធនធានទឹកផ្សេងទៀត។
- កិច្ចប្រជុំពិគ្រោះយោបល់ដ៏ទូលំទូលាយជាមួយសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដោយទំនប់ ប៉ាក់ បេង រួមមានសហគមន៍ក្នុងប្រទេសជិតខាងផងដែរ ត្រូវតែមាន ដោយអនុលោមតាមបទដ្ឋានអន្តរជាតិនានា មុនពេលធ្វើការសម្រេចចិត្តណាមួយលើគម្រោងនេះ។

បច្ចុប្បន្នភាពនៃការសិក្សាគម្រោង ត្រូវតែដាក់ជូនគណៈកម្មការទន្លេមេគង្គ (MRC) ពិនិត្យដោយក្រុមបច្ចេកទេសរបស់ MRC ហើយក៏ត្រូវផ្ញើរទៅប្រទេសសមាជិក MRC ស្របតាមនីតិវិធីពិគ្រោះយោបល់ជាមុន។ ការសម្រេចចិត្ត ការត្រៀមរៀបចំ និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងទំនប់ ប៉ាក់ បេង ត្រូវតែពន្យាពេល រហូតដល់មានព័ត៌មានលំអិតគ្រប់គ្រាន់ដើម្បីវាយតម្លៃហេតុប៉ះពាល់គម្រោងឱ្យបានគ្រប់ជ្រុងជ្រោយក្នុងបរិបទអាងទន្លេមេគង្គ។ បន្ទាប់ពីមានការសិក្សាស្រាវជ្រាវគម្រោងយ៉ាងគ្រប់គ្រាន់ តាមរយៈការវាយតម្លៃឯករាជ្យ ទើបកិច្ចប្រជុំពិគ្រោះយោបល់តាមតំបន់ និងការសម្រេចចិត្តលើទំនប់ ប៉ាក់ បេង អាចត្រូវបានអនុញ្ញាតឱ្យមានដំណើរការ ។